**BMI0194**

# សម្ភាសន៍ជាមួយឈ្មោះ ដាម គិន ភេទស្រី អាយុ៥៩ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហមៈ ប្រពន្ធតាវ៉ាល់

ស្រុកកំណើតនៅភូមិមុខឈ្នាង ឃុំស្ពានស្រែង ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ

រស់នៅភូមិស្ពានក្មេង ឃុំភ្នំដី ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ

ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០០:២៨:៥៣

១៥ទំព័រ

ដានី : អឺចឹងអ៊ឹងប្អូនខ្ញុំសុំស្គាល់ឈ្មោះអ៊ំឈ្មោះអីទៅ?

គិន : ឈ្មោះខ្ញុំ ឈ្មោះដាម គិន ។

ដានី : គាម គិនហ្អី?

គិន : ដាម ដាម គិន ។

ដានី : ហ៊ាម ហ្អី?

គិន : ដាម ឈ្មោះដាម ។

ដានី : ឈ្មោះដាម?

គិន : ដាម គិន ។

ដានី : ដាម គិន?

គិន : ចា៎!

ដានី : ចុះអ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

គិន : ៥៩ ។

ដានី : អាយុ៥៩ឆ្នាំ?

គិន : ចា៎!

ដានី : អ៊ំស្រុកកំណើតកើតជានៅឯណាទៅ?

គិន : នៅមុខឈ្នាង ។

ដានី : ភូមិអីគេអាហ្នឹង?

គិន : ភូមិមុខឈ្នាង ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ដានី ៖ ភូមិមុខឈ្មៀង?

គិន ៖ ចាស ឃុំស្ពានស្រែង ។

ដានី ៖ ឃុំស្ពានស្រែង?

គិន ៖ ចាស ស្រុកភ្នំស្រុក ។

ដានី ៖ ស្រុកភ្នំស្រុក?

គិន ៖ ចា៎!

ដានី ៖ ខេត្ត?

គិន ៖ ខេត្តបន្ទាយមានជ័យ ។

ដានី ៖ ចុះសព្វថ្ងៃអ៊ំនៅភូមិឃុំអីដែរ?

គិន ៖ គេហៅគោកធំ គេហៅស្ពានក្មេង ភូមិស្ពានក្មេង ។

ដានី ៖ ភូមិស្ពានក្មេង?

គិន ៖ ចា៎!

ដានី ៖ ឃុំអីហ្នឹង?

គិន ៖ ភូមិស្ពានក្មេង ឃុំភ្នំដី ។

ដានី ៖ ឃុំភ្នំដី?

គិន ៖ ចា៎!

ដានី ៖ ស្រុកអីដែរ?

គិន ៖ ស្រុកភ្នំស្រុក ។

ដានី ៖ ខេត្ត?

គិន ៖ ខេត្តដូចតែគ្នា ។

ដានី ៖ ខេត្តបន្ទាយមានជ័យ?

គិន ៖ ចា៎!

ដានី ៖ អ៊ំឪពុកអ៊ំគាត់ឈ្មោះអីទៅ?

គិន ៖ ឪពុកខ្ញុំឈ្មោះណាប់ ។

ដានី ៖ ឪពុកឈ្មោះណាប់?

គិន ៖ ចា៎!

ដានី ៖ ស្អីណាប់ទៅ?

គិន ៖ ស្អី ខ្ញុំភ្លេចហើយ ។

ដានី ៖ ឈ្មោះណាប់ ឥឡូវគាត់នៅឬក៏ស្លាប់ហើយ?

គិន ៖ ស្លាប់ហើយ ស្លាប់យូរណាស់ហើយ ស្លាប់តាំងពីខ្ញុំអាយុ៨ ៩ឆ្នាំ ។

ដានី ៖ ស្លាប់តាំងពីអ៊ំអាយុ៨ ៩ឆ្នាំ?

គិន ៖ ចា៎!

ដានី ៖ ចុះម្ដាយអ៊ំឈ្មោះអីទៅ?

គិន ៖ ឈ្មោះវ៉ន ស៊ុត វ៉ន ។

ដានី ៖ បាទ!

គិន ៖ ស៊ុត វ៉ន ។

ដានី ៖ គាត់នៅរស់ឬស្លាប់ហើយ?

គិន ៖ ស្លាប់ហើយ ស្លាប់បួនដប់ឆ្នាំជាងហើយ ។

ដានី ៖ ស្លាប់បួនដប់ឆ្នាំហើយ?

គិន ៖ ចា៎!

ដានី ៖ ចុះអ៊ំមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

គិន ៖ បងប្អូនប្រាំបីនាក់ ។

ដានី ៖ បាទ?

គិន ៖ បងប្អូនខ្ញុំប្រាំបីនាក់ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

គិន ៖ ស្រី ពីរ បី បួន ប្រាំ ស្រីប្រាំ ។

ដានី ៖ ស្រីប្រាំប្រុសបី?

គិន ៖ ចា៎!

ដានី ៖ ចុះអ៊ំកូនទីប៉ុន្មាន?

គិន ៖ មិនដឹងទីប៉ុន្មាន ។

ដានី ៖ ចុះអ៊ំ ទីមួយឈ្មោះអី?

គិន ៖ ទីមួយឈ្មោះតាប់ ជាម តាប់ ។

ដានី ៖ ជាម តាប់ហ្អី?

គិន ៖ ចា៎!

ដានី ៖ គាប់ ស្រីឬប្រុស?

គិន ៖ ប្រុស ។

ដានី ៖ សព្វថ្ងៃគាត់នៅឯណា?

គិន ៖ នៅអីរេាង ។

ដានី ៖ បាទ?

គិន ៖ នៅអីរេាង ទៅនៅស្រុករេាង ។

ដានី ៖ ស្រុករេាង?

គិន ៖ ចាំ!

ដានី ៖ ទៅនៅស្រុករេាង?

គិន ៖ ចាស ទៅនៅស្រុករេាង ។

ដានី ៖ ឃុំអីគេដែរ?

គិន ៖ ឃុំស្ពានស្រែង ។

ដានី ៖ នៅភូមិរេាង ឃុំស្ពានស្រែង?

គិន ៖ ចាំ!

ដានី ៖ ចុះទីពីរឈ្មោះអីគេ?

គិន ៖ ទីពីរឈ្មោះកែវ ដាម កែវ ។

ដានី ៖ ស្រីឬប្រុស?

គិន ៖ ស្រី ។

ដានី ៖ គាត់នៅឯណាដែរ?

គិន ៖ នៅនេះឯង ។

ដានី ៖ បាទ?

គិន ៖ នៅភូមិនេះឯង ។

ដានី ៖ នៅភូមិ...

គិន ៖ ភូមិជាមួយគ្នា ភូមិភ្នំដី ។

ដានី ៖ ឃុំស្ពានក្មេង?

គិន ៖ ចាំ!

ដានី ៖ ចុះទីបី?

គិន ៖ ទីបីឈ្មោះឆាយ ឈ្មោះឆឹត ។

ដានី ៖ ជាម ឆឹត ។

គិន ៖ ជាម ឆឹត ឥឡូវបាត់ ។

ដានី ៖ នៅឯណា?

គិន ៖ មិនដឹងនៅឯណា ។

ដានី ៖ បាត់ខ្លួនហ្អី ស្រីឬប្រុស?

គិន ៖ ប្រុស ។

ដានី ៖ ប្រុស ចុះទីបួន?

គិន ៖ ទីបួនឈ្មោះ ជាម ឆាយ ។

ដានី ៖ ទីបួនឈ្មោះ ជាម ឆាយ?

គិន ៖ ចាស ។

ដានី ៖ ស្រីឬប្រុស?

គិន ៖ ប្រុស ។

ដានី ៖ គាត់នៅឯណាដែរ?

គិន ៖ នៅភូមិជាមួយគ្នានេះឯង ។

ដានី ៖ នៅភូមិស្ពានក្មេងជាមួយគ្នា?

គិន ៖ ចា៎!

ដានី ៖ ចុះទីប្រាំ?

គិន ៖ ទីប្រាំឈ្មោះ ជាម គន ។

ដានី ៖ ជាម គន?

គិន ៖ ជាម គន ស្រី ។

ដានី ៖ គាត់នៅឯណាដែរ?

គិន ៖ នៅជាមួយគ្នានេះឯង ។

ដានី ៖ នៅស្ពានក្មេងដែរ?

គិន ៖ ចា៎!

ដានី ៖ ចុះទីប្រាំមួយ?

គិន ៖ ទីប្រាំមួយខ្ញុំ ។

ដានី ៖ ទីប្រាំមួយអ៊ីផ្ទាល់ ចុះទីប្រាំពីរ?

គិន ៖ ទីប្រាំពីរប្អូននៅអីរេងឈ្មោះ ដាម គាំ ។

ដានី ៖ ដាម គាំ?

គិន ៖ ចា៎!

ដានី ៖ នៅរេងនៅខាងស្ពានស្រែង?

គិន ៖ ចា៎!

ដានី ៖ ទីប្រាំបី?

គិន ៖ ទីប្រាំបីឈ្មោះ ដាម គាប់ ។

ដានី ៖ ដាម គាប់ នៅឯណាដែរ?

គិន ៖ នៅអីរេងដែរ ។

ដានី ៖ នៅរេង ស្ពានស្រែងដែរ?

គិន ៖ ចា៎!

ដានី ៖ ចុះអ៊ីកាលក្មេងៗ រៀនបានដល់ណាដែរ?

គិន ៖ ខ្ញុំមិនបានរៀនទេ ។

ដានី ៖ អត់បានរៀនទេ?

គិន ៖ ទៅសាលារៀន ទៅសាលារៀននៅភូមិក៏រៀន ដល់កាលសម័យ លន់ នល់ មានបានរៀន សូត្រអី ។

ដានី ៖ រៀនថ្នាក់ទីប៉ុន្មានដែរ?

គិន ៖ កាលនោះមិនទាន់បានឡើងថ្នាក់ឡើងអីផង ក៏ឈប់រៀនរត់កាលសម័យ លន់ នល់ ក៏រត់ គេជម្លៀសមកនៅបៀតស្ពានធំ ស្ពានក្មេងនេះហើយមិនបានរៀនបានសូត្រអី ។

ដានី ៖ អ៊ីចេះអានចេះសរសេរទេ?

គិន ៖ មានចេះអី មិនចេះអានចេះសរសេរ ។

ដានី ៖ អត់ចេះអានចេះសរសេរទេ?

គិន ៖ អត់ទេ ។

ដានី ៖ រៀនបានប៉ុន្មានឆ្នាំ?

គិន ៖ ខ្ញុំរៀនបានពីរឆ្នាំ បីឆ្នាំតែមិនចេះអីបន្តាក់បន្តិច ។

ដានី ៖ ហើយយ៉ាងម៉េចទៅអ៊ីឈប់រៀនឆ្នាំណា?

គិន ៖ ខ្ញុំឈប់រៀនពីឆ្នាំប៉ុន្មាន ឆ្នាំ កាលឆ្នាំ៧៧ ហួស!៧៣ គេជម្លៀសខ្ញុំទៅនៅខាងភូមិ គេហៅយោធាៗណាស ជម្លៀសយកទៅណោះទៅរៀននៅឯណោះអីខាងតំបន់គេណោះ តំបន់ប្រាំ ។

ដានី ៖ ជម្លៀសទៅណា?

គិន ៖ តំបន់ប្រាំ តំបន់សាមប្រាំហ្អី អីខាងសៀមរាបណាស!

ដានី ៖ ហួស!ជម្លៀសទៅតំបន់សាមប្រាំហ្អី?

គិន ៖ ចាំ!

ដានី ៖ នៅម្តុំណាដែលជម្លៀសទៅ?

គិន ៖ នៅបៀតខ្នា គេហៅស្រុកខ្នា ។

ដានី ៖ តំបន់សាមប្រាំនៅខ្នាហ្អី?

គិន ៖ ចាំ!

ដានី ៖ ខ្នានៅស្រុកអីគេទៅ?

គិន ៖ ស្រុកអីទេ ខ្ញុំមិនចាំ ។

ដានី ៖ អាចថាស្រុកក្រឡាញ់ឬក៏ស្រុកអី?

គិន ៖ ស្រុកក្រឡាញ់ហ្នឹងឯង ។

ដានី ៖ ស្រុកក្រឡាញ់ហ្អី?

គិន ៖ ចាស ខ្ញុំមិនសូវចាំ ដល់ទៅនៅក្មេងៗក៏ស៊ិតជងកាលនោះ ។

ដានី ៖ ឆ្នាំ៧៣ហ្នឹងយោធាខាងណាមកជម្លៀសហ្នឹង?

គិន ៖ យោធាខាងតំបន់សាមប្រាំ ។

ដានី ៖ យោធាតំបន់សាមកប្រាំខាងខ្មែរក្រហមឬខាង លន់ នល់?

គិន ៖ ខាងខ្មែរក្រហម ។

ដានី ៖ ខ្មែរក្រហមហ្អី?

គិន ៖ ចាំ!

ដានី ៖ កាលនោះគេជម្លៀសតែអ៊ីទៅឬទៅច្រើន?

គិន ៖ ជម្លៀសទៅច្រើន ជម្លៀសទៅម៉ាភូមិណាសនៅអីណោះខ្លះបងខ្ញុំនៅឯណោះខ្លះ គេធ្វើទាហានទៅក៏គេចាប់ទាហាន គាត់នៅឯណោះទៅតែខ្ញុំម៉ែខ្ញុំទៅតែប្អូនៗ នៅបង ។

ដានី ៖ ចឹងទៅតែអ៊ី ម្តាយ ហើយប្អូនប៉ុន្មាននាក់ទៅជាមួយគ្នា?

គិន ៖ ពីរនាក់ បងម្នាក់បងគេបង្អស់នោះដងគាត់ទៅមុនខ្ញុំ ដល់គេបាញ់ស្រុករោងនោះគាត់មក យកពួកម៉ែពួកខ្ញុំទៅនៅតំបន់ខាងតំបន់ខាងសៀមរាប ។

ដានី ៖ អីចឹងអ្នកភូមិជាមួយអ៊ំនៅមុខឈ្មោងហ្នឹងទៅដែរអត់?

គិន ៖ ទៅ ទៅខ្លះ ។

ដានី ៖ ចុះខ្លះ?

គិន ៖ ទៅខ្លះ អាណាដែលគេទាញបានមកណេះ លន់ នល់ ទាញបានមកណេះខ្លះទៅណោះខ្លះ ។

ដានី ៖ អីចឹងអ្នកដែលនៅក្នុងភូមិយើងអត់ទៅ នៅជាមួយ លន់ នល់?

គិន ៖ ចាំ! នៅនេះមានតែអ្នកធ្វើទាហានទេ ធ្វើទាហានទៅមិនរួច ។

ដានី ៖ ចុះអ៊ំនៅកន្លែងរំដោះតំបន់សាមប្រាំនៅខ្នារហ្នឹងទៅបានរយៈពេលប៉ុន្មានទៅ?

គិន ៖ ពីឆ្នាំ៧៣ ដល់ឆ្នាំ៧៤ខ្ញុំ គេឲ្យធ្វើយោធា នែ! ធ្វើមិត្តនារី ។

ដានី ៖ ឆ្នាំ៧៤ អ៊ំធ្វើមិត្តនារីហ្អី?

គិន ៖ ចាំ!

ដានី ៖ មិត្តនារីធ្វើអីខ្លះទៅ?

គិន ៖ ឲ្យច្បាំងជាមួយល លន់ នល់ ។

ដានី ៖ បាទ?

គិន ៖ គេឲ្យច្បាំងជាមួយ លន់ នល់ ។

ដានី ៖ ទ័ពហ្អី?

គិន ៖ ចាំ! កងទ័ព ។

ដានី ៖ កាលនោះអ៊ំអាចរៀបរាប់ឲ្យច្បាស់បានទេថាហេតុអីបានអ៊ំចូលមិត្តនារី?

គិន ៖ គេ ចលនាគេ ចលនាឲ្យយើងចូលជាមួយគេដល់យើងប្រជាជនទៅតាមគេ តាមអង្គការគេ ជ្រើសរើសយកក៏ទៅតាមដល់ខ្ញុំមកឆ្នាំ៧៤ឆ្លងមកនេះហើយខ្ញុំទៅនៅតាដូគេបញ្ជូនទៅតាដូ ស្វាយចេក ។

ដានី ៖ តាដូហ្នឹងភូមិឬស្អីគេ?

គិន ៖ ភូមិតាដូមិនដឹងថាភូមិអីខ្ញុំក៏មិនចាំកាលនោះទៅនៅតែក្នុងព្រៃ ។

ដានី ៖ កាលឆ្នាំ៧៤មានចលនាជ្រើសរើសឲ្យធ្វើខ្មែរក្រហមកាលនោះមានគ្នាប៉ុន្មាននាក់ដែរអ៊ំ?

គិន ៖ ចូលច្រើនណាស់តែខ្ញុំមិនចាំ ចូលទាំងស្រុកគេស្រុកឯង ចាំខ្លះនៅក្នុងភូមិយើងមានខ្លះ ខ្លះក៏ បាត់ខ្លួន ងាប់កាលដែលពួកដែលពួកនិរតីចូលមក ។

ដានី ៖	កាលនោះអ៊ំអាយុប៉ុន្មាន?

គិន ៖	ខ្ញុំអាយុ១៧ ។

ដានី ៖	១៧ ហើយកាលប្រធានដែលគេមកធ្វើចលនា ខ្មែរក្រហមដែលគេមកឃោសនាដែលដឹកនាំអ៊ំចូលហ្នឹងគាត់ឈ្មោះអី?

គិន ៖	ឈ្មោះម៉ៅ ឆាប់អស់ហើយ ។

ដានី ៖	ម៉ៅហ្នឹងស្រីឬប្រុស?

គិន ៖	ប្រុស ។

ដានី ៖	ម៉ៅហ្នឹងគាត់ធ្វើប្រធានអីទៅ?

គិន ៖	ធ្វើប្រធានចលនាប្រជាជន ធ្វើប្រធានអប់រំចលនាប្រជាជន ឲ្យប្រជាជនចូលធ្វើកងទ័ពធ្វើយោធា ។

ដានី ៖	ម៉ៅហ្នឹងប្រធានចលនាអប់រំប្រជាជននៅឯណាទៅ?

គិន ៖	ពីដើមមិញនៅស្រុកព្រៃដល់នេះក៏គេចាប់អាគេចូលមកហ្នឹង តែឥឡូវស្លាប់អស់ហើយគ្មានអ្នកណារស់មួយទេ ។

ដានី ៖	បាទ!តែកាលគាត់ធ្វើប្រធានឃោសនាអ៊ំហ្នឹងគាត់ជាប្រធាននៅម្តុំណា?

គិន ៖	ស្រុកព្រៃ ។

ដានី ៖	ស្រុកព្រៃហ្នឹងនៅស្រុកណា?

គិន ៖	ព្រៃស្រុក ភូមិព្រៃ ស្រុកស្រីស្នំ ។

ដានី ៖	ចុះអ៊ំដល់ចូលកងទ័ពហើយយើងមានហាត់ក្បួនយុទ្ធសាស្រ្តកងទ័ពដែរអត់?

គិន ៖	ចាស ហាត់ ។

ដានី ៖	ហាត់នៅឯណា?

គិន ៖	ហាត់នៅព្រៃ ព្រៃខាងសៀមរាប ។

ដានី ៖	ហាត់ក្នុងព្រៃ?

គិន ៖	ចាំ!

ដានី ៖	ហាត់រយៈពេលប៉ុន្មានទៅ?

គិន ៖	ហាត់តែពីរខែបីខែ ។

ដានី ៖	គ្នាប៉ុន្មាននាក់ដែលហាត់?

គិន ៖	ច្រើនម៉ាស្រុកភូមិខ្ញុំ គេទៀតវាច្រើនវាលាយគ្នាចាំវាបាន ។

ដានី ៈ ប្រហែលប៉ុន្មាននាក់?

គិន ៈ កងទ័ពផងយោធាផងមិនដល់១០០នាក់ទេ ។

ដានី ៈ កាលនោះមានតែនារីៗឬមានបុរសដែរ?

គិន ៈ មាន យោធា ។

ដានី ៈ យោធាហ្នឹងមាននារី...

គិន ៈ នារីយើងហៅសេនាជន ខាងនោះ ។

ដានី ៈ ហើយចុះប្រធានដែលគ្រប់គ្រងពេលហាត់១០០នាក់ហ្នឹងឈ្មោះអីទៅ?

គិន ៈ ឈ្មោះ សន ។

ដានី ៈ ឈ្មោះ សន ហ្អី?

គិន ៈ ចាំ!

ដានី ៈ ស្រីឬប្រុស?

គិន ៈ ប្រុស ។

ដានី ៈ ចឹងកាលនោះអ៊ីទៅចូលរួមកងទ័ពនៅខាងសៀមរាប?

គិន ៈ ចាំ!

ដានី ៈ កាលនោះនៅក្នុងភូមិភាគអីគេ?

គិន ៈ ភូមិភាគ គេហៅភូមិភាគអីទេខ្ញុំភ្លេច ចាំអត់បាន ។

ដានី ៈ ប៉ុន្តែដល់ពេលអ៊ីហាត់យុទ្ធសាស្ត្រកងទ័ពរយៈពេលពីរខែហើយយ៉ាងម៉េចទៀត?

គិន ៈ ដល់ហាត់រួចគេបញ្ជូនយើងទៅខាងភ្នំស្រុកវិញ ។

ដានី ៈ ឆ្លងមកភ្នំស្រុកវិញ?

គិន ៈ ចាំ!ទៅនៅអីពង្រ នៅតាដូអីណោះ ។

ដានី ៈ បាទ នៅពង្រ នៅតាដូ នៅធ្វើអីទៅនៅនោះ?

គិន ៈ ធ្វើកងទ័ពហ្នឹងហើយ ។

ដានី ៈ ប៉ុន្តែកងទ័ពធ្វើអីដែរពេលនោះ?

គិន ៈ បាញ់ជាមួយហ្នឹង លន់ នល់ ។

ដានី ៈ បាញ់ជាមួយ លន់ នល់?

គិន ៈ ចាំ!

ដានី ៈ កាលនោះអ៊ីបានបាញ់ជាមួយទាហាន លន់ នល់ ដែរ?

គិន ៖ គេឲ្យឡើងទៅបាញ់ហ្នឹង នែ!ខ្លាចគេមិនបានបាញ់អីទេ ចុះគេដោះស្រីៗទៅបាញ់អីហ្គាស តែរត់ វាចេះតែឲ្យយើងទៅ ទៅ លន់ នល់ គេបាញ់ រត់ចាំផាប់ខ្លះរស់ខ្លះ ។

ដានី ៖ កាលនោះចាំមកស្វាយចេកហ្នឹងមកគ្នាច្រើនទេ?

គិន ៖ ច្រើនខ្ញុំចាំមិនអស់ថាប៉ុន្មានកងៗខ្ញុំចាំមិនបានទេ ។

ដានី ៖ កាលនោះពីណាគេអ្នកដឹកនាំ ដែលដឹកនាំមកស្វាយចេក?

គិន ៖ អង្គការគេ តែមិនដឹងអង្គការឈ្មោះអី ។

ដានី ៖ ដូចថាប្រធានគ្រប់គ្រងកងទ័ព?

គិន ៖ ប្រធានគ្រប់គ្រងនោះ ចាំដូចថាខាងនារីឈ្មោះ ភ័ណ ។

ដានី ៖ ឈ្មោះ ភ័ណ ហ្អី?

គិន ៖ ចុះខាងបុរស?

ដានី ៖ ខាងបុរសឈ្មោះ ម៉ោង ឈ្មោះ សន ។

គិន ៖ ឈ្មោះ តាម៉ោងហ្នឹងហ្អី?

ដានី ៖ តាម៉ោង ហ្នឹងហ្អី?

គិន ៖ ចា៎!

ដានី ៖ តាម៉ោង ហើយ តាសន?

គិន ៖ ចា៎!

ដានី ៖ ហ្នឹងគាត់ប្រធានខាងបុរសហើយខាងនារីឈ្មោះ ភ័ណ?

គិន ៖ ចា៎!

ដានី ៖ ចុះកាលនោះអ៊ីមានតួនាទីអីហ្នឹងគេដែរអត់?

គិន ៖ ទេ ខ្ញុំអត់មានតួនាទីអីទេ គេឲ្យធ្វើតែកូនចៅគេ ចេះតែទៅតាមគេចោលម៉ែឪនៅអីតំបន់ សៀមរាមនោះ កូនៗគេបញ្ជូនមកនេះ ។

ដានី ៖ ចុះអ៊ីដូចយើងវៃជាមួយ លន់ នល់ នៅខាងស្វាយចេកហ្នឹងរយៈពេលប៉ុន្មានទៅ?

គិន ៖ នៅនោះ ខ្ញុំនៅនឹងតាដូចាល់តែឆ្នាំ៧៤ ឆ្នាំ៧៥បានចប់សង្គ្រាម ។ ដល់ឆ្នាំ៧៤ទៅនៅអី នោះ ឆ្នាំ៧៥ក៏ចប់អង្គការឲ្យទៅនៅអីថ្មពួក ។

ដានី ៖ អ៊ីចឹងពេលបែក៧៥ហ្នឹងអង្គការឲ្យទៅនៅថ្មពួក?

គិន ៖ ចា៎!

ដានី ៖ ទៅថ្មពួកធ្វើអីទៅ?

គិន ៖ ទៅថ្មពួកដើរចលនាប្រជាជន ។

ដានី ៖ ដើរចលនាប្រជាជនម៉េចទៅ?

គិន ៖ ជីកទំនប់ លើកទំនប់ ជីកប្រឡាយ ។

ដានី ៖ អីចឹងអ៊ំមានតួនាទីអីពេលទៅ?

គិន ៖ អត់ទេ ខ្ញុំមិនមានធ្វើអីទេព្រោះខ្ញុំជាប់ប្រវត្តិបងធ្វើទាហាន អត់មានធ្វើអីទេគេឲ្យធ្វើតែកូនចៅគេ ។

ដានី ៖ កាលនោះអ៊ំនៅកងអីគេទៅដែលយើងនៅក្នុងចលនាប្រជាជនចឹង?

គិន ៖ កងគេហៅកងយោធា ហួស!កងសេនាជន ។

ដានី ៖ ពីណាគេធ្វើប្រធាន?

គិន ៖ បងភ័ណ ។

ដានី ៖ ភ័ណ ស្រីហ្អី?

គិន ៖ ស្រី ។

ដានី ៖ ចុះភ័ណ សព្វថ្ងៃគាត់នៅឯណា?

គិន ៖ មិនដឹងនៅឯណា នៅសំឡូតនៅអីទេដឹង ងាប់ហើយ គាត់ងាប់កាលពី៧៥ ។

ដានី ៖ អីចឹងអ៊ំនៅថ្មពួកនោះរយៈពេលបានប៉ុន្មាន?

គិន ៖ ខ្ញុំនៅបានប៉ុន្មានខែក្នុងឆ្នាំ៧៥ នៅបានម៉ាខែទៅនៅស្វាយ ។

ដានី ៖ អីចឹងនៅបានម៉ាខែមកនៅស្វាយ?

គិន ៖ចា៎!

ដានី ៖ ហេតុអីបាននៅបានតែម៉ាខែមកនៅស្វាយ?

គិន ៖ គេចេះតែបញ្ជូនឲ្យឯងមកនៅខាងស្វាយវិញ ។

ដានី ៖ ពេលមកស្វាយធ្វើអីវិញ?

គិន ៖ ធ្វើចលនាប្រជាជនប្រជាជនលើកទំនប់ លើកភ្លឺ លើកប្រឡាយដើរធ្វើការជាមួយប្រជាជនស្ទូង ដក ។

ដានី ៖ ចុះអ៊ំបានជួបជាមួយ តាវ៉ាល់ ពេលណាដែរ?

គិន ៖ គាត់ស្នើខ្ញុំកាលឆ្នាំ៧៤ ដល់ឆ្នាំ៧៥ ខែប្រាំទៅក៏ចាប់ការ ។

ដានី ៖ អីចឹងអ៊ំបានជួបជាមួយ តាវ៉ាល់ តាំងពីឆ្នាំ៧៤ហ្អី?

គិន ៖ ចា៎!

ដានី ៖ អ៊ំជួបគាត់ពេលណា នៅកន្លែងណា?

គិន ៖ ជួបនៅកន្លែងយោធា យោធាគេនៅខាងសៀមរាប ។

ដានី ៖ ជួបគាំងពីនៅកន្លែងសៀមរាប?

គិន ៖ ចាស នៅជាមួយគ្នា ។

ដានី ៖ នៅកន្លែងណា?

គិន ៖ ជួបនៅបៀតព្រៃ គេហៅថាស្រុកព្រៃ ។

ដានី ៖ ស្រុកព្រៃ?

គិន ៖ ចាស នៅក្នុងព្រៃ ។

ដានី ៖ កាលអ៊ំជួបគាត់កាលនោះគាត់ធ្វើអី?

គិន ៖ គាត់ធ្វើយោធា ។

ដានី ៖ គាត់ធ្វើយោធា?

គិន ៖ ចាំ!

ដានី ៖ គាត់ធ្វើយោធាបានន័យថាតួនាទីគាត់ធ្វើអីទៅ?

គិន ៖ គាត់ប្រធាន គេឲ្យគាត់ធ្វើប្រធានក្រុម ។

ដានី ៖ ប្រធាមក្រុម?

គិន ៖ ចាំ!

ដានី ៖ ប្រធានក្រុម គាត់ធំជាងតាសនប៉ុយ៉ាងម៉េច?

គិន ៖ ទេ តូចប្រធានក្រុមបើគេប្រធានម៉ាកង៏ទ័ពគេប្រធាន ដូចប្រធានគរប្រធានអីសព្វថ្ងៃ ។

ដានី ៖ ចុះតាម៉ោង...?

គិន ៖ ចាស តាម៉ោង ហើយ តាសន គេដូចសមាជិក គេសមាជិករង ។ គេធ្វើការដូចថាប្រធាន កង អនុកង ។

ដានី ៖ ចឹងកាលនោះ តាវ៉ាល់ គាត់តូចជាងតាម៉ោង តាសន អីទេ?

គិន ៖ ចាស ។

ដានី ៖ គាត់ជាប្រធានក្រុមនៅក្នុងយោធាហ្នឹង?

គិន ៖ ចាំ!

ដានី ៖ ចុះ តាវ៉ាល់ គាត់អ្នកស្រុកណាដែរ?

គិន ៖ អ្នកកំពង់ចាម ។

ដានី ៖ អ្នកកំពង់ចាមនៅស្រុកណា?

គិន ៖ មិនដឹងថានៅស្រុកអីខ្ញុំមិនដែលសួរ កាលនោះខ្ញុំឆោត អាយុច្រើនតែឆោតមិនសួរមិនអី មិនដឹងថាប្តីនៅភូមិអី គេថានៅឆ្ងាយណាស់កំពង់ចាម ។ ខ្ញុំម៉មិនបានសួរថាកំពង់ចាមៗក៏មិនបានសួរ ។

ដានី ៖ ចុះឈ្មោះគាត់ឈ្មោះដើមគេហៅឈ្មោះអី?

គិន ៖ ឈ្មោះដើមគេហៅឈ្មោះ ឃុន ។

ដានី ៖ ឈ្មោះ ខុន?

គិន ៖ ចាំ!

ដានី ៖ ហើយឈ្មោះអីទៀត?

គិន ៖ ខ្លះគេហៅឈ្មោះ ហួន ។

ដានី ៖ ហួន ហ្អី?

គិន ៖ ចាំ!មកនេះទៅក៏គេហៅតែ តាវ៉ាល់ៗ ។

ដានី ៖ ឈ្មោះ តាវ៉ាល់ហ្នឹងគេចាប់ផ្តើមហៅពីពេលណា?

គិន ៖ មិនដឹងខ្ញុំទើបតែចូលដែរក៏មិនដឹង ។

ដានី ៖ ចុះកាលឆ្នាំ៧៨ពេលដែលអ៊ីជួបគាត់នៅស្រុកព្រៃហ្នឹងណាស ពេលហ្នឹងគាត់ប្រើឈ្មោះអី?

គិន ៖ មិនដឹងឈ្មោះអីខ្ញុំឮតែគេថា វ៉ាល់ៗចឹង ។

ដានី ៖ ចុះឈ្មោះ ខុន ឈ្មោះ ហួនហ្នឹងគេប្រើឈ្មោះហ្នឹងអត់?

គិន ៖ គេហៅម្នាក់ៗ

ដានី ៖ ចុះឈ្មោះដើមរបស់គាត់ ឈ្មោះពីកំណើតហ្នឹងឈ្មោះអី?

គិន ៖ មិនដឹង គេហៅតែខុនៗទៅ ខ្ញុំមិនដឹងឈ្មោះគាត់ផង ។

ដានី ៖ ឈ្មោះខុន ឈ្មោះហួន?

គិន ៖ ចាំ!

ដានី ៖ ចុះត្រកូលគាត់ឈ្មោះអី?

គិន ៖ មិនស្គាល់ទេ ។

ដានី ៖ អត់ដឹងឈ្មោះពេញដូចអ៊ីឈ្មោះ ដាម គិន ចឹងហើយគាត់ឈ្មោះអី ។

គិន ៖ មិនដឹងហ្អាក មិនដឹងនាមត្រកូលគាត់ឈ្មោះអី ។

ដានី ៖ អត់ដឹងថានាមត្រកូលគាត់ឈ្មោះអីទេ?

គិន ៖ អត់ទេ មិនដឹង ។

ដានី ៖ ចុះឪពុកគាត់ឈ្មោះអី?

គិន ៖ មិនដឹង មិនដែលបានឃើញពុកមិនដែលឃើញម៉ែផង ។

ដានី ៖ ចុះគាត់មានដែលនិយាយប្រាប់ទេ?

គិន ៖ ទេ មិនដែលបាននិយាយប្រាប់ទេ ។

ដានី ៖ ចុះម្ដាយ?

គិន ៖ ម្ដាយក៏មិនដឹងឈ្មោះអីមិនដែលបានឃើញ មិនដែលបានស្គាល់គាត់ បើគាត់នៅផ្សេង ខ្ញុំក៏នៅផ្សេងដល់តែបានប្ដីបានប្រពន្ធទៅខ្ញុំក៏នៅបន្តុបន្ថែមផល ។

ដានី ៖ ចុះបងប្អូនគាត់អីមានដែលបានឃើញបានស្គាល់ទេ?

គិន ៖ ទេ មិនដែលឃើញទេ ។

ដានី ៖ អត់ដែលឃើញបងប្អូនគាត់បង្កើតអីទេ?

គិន ៖ មិនដែលឃើញទេ មិនដែលស្គាល់ ។

ដានី ៖ ចុះគាត់នៅហ្នឹងបងប្អូនឪពុកម្ដាយអីអត់ដែលមកទេ?

គិន ៖ ទេ ។

ដានី ៖ ចុះគាត់ដែលទៅលេងស្រុកកំណើតទេ?

គិន ៖ ទេ មិនដែលបានទៅ ។

ដានី ៖ គាត់អត់ដែលបានទៅលេងស្រុកកំណើតទេតាំងពីការហើយ?

គិន ៖ អត់ទេ ។

ដានី ៖ អ៊ឹអត់ដែលឮថាឪពុកគាត់ឈ្មោះអីម្ដាយឈ្មោះអីទេ?

គិន ៖ ទេ ។

«ចប់»